# ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៥

ស្ដីពី

វិសោធនកម្មមាត្រា ៨, មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ

នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០

ស្ដីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង

សង្គ្រោះជនពិការដោយសារមីន

យើង

ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ រដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្ដីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

# ត្រាស់បង្គាប់

## មាត្រា មួយ :

មាត្រា ៤. មាត្រា ១០. មាត្រា១១ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវធ្វើវិសោធនកម្មដូចតទៅ÷

**មាត្រា ៤ ថ្មី : អ.ក.គ.ម.ស.ព.ម.** មានសមាសភាព ដូចតទៅ:

- សម្តេចនាយករដ្ឋមន្ត្រី ជាប្រធាន
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ទី១
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ទី២
- ឥស្សរៈជនជាន់ខ្ពស់ ១ រូប ជាអគ្គលេខាធិការ
- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ជាសមាជិក
- តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិក
- តំណាងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាសមាជិក
- តំណាងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាសមាជិក
- តំណាងអគ្គស្នងការនគរបាលជាតិ ជាសមាជិក
- តំណាងអាជ្ញាធរអប្សរា ជាសមាជិក
- ឥស្សរជនជាន់ខ្ពស់ជំនាញច្បាប់ ១ រូប ជាសមាជិក

**អ.ក.គ.ម.ស.ព.ម.** មានអគ្គលេខាធិការដ្ឋានជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការ ០១ រូប ។



3/4

មាត្រា ១០ ថ្មី : សម្តេចនាយករដ្ឋមន្ត្រីអាចស្នើតែងតាំងអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ជាជំនួយការអគ្គលេខាធិការ ។ អគ្គលេខាធិការរងនីមួយៗ ត្រូវទទួលបន្ទុកតាមការចាត់តាំងរបស់អគ្គលេខាធិការ ។

មាត្រា ១៣ ថ្មី : អ.គ.គ.ម.ស.ព.ម. មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ពីរ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា បី : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា បួន : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។៚

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧-០៥០៦.៤៨១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ១២៤៥ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ានិត